ដែលត្រូវផ្លាស់អោយមកបំរើការងារនៅក្នុងប្រទេសវិញដោយចប់អាណត្តិ ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងស្ថាប័នពាក់ព័ន្ធ និងលោក **ឡុង ផុល** ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឬទ្ធិ** | **ហ៊ុន សែន** |

* * *

# ២ - សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ : ២៨ សសរ**

**ស្តីពីការផ្ទេរសិទ្ធិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

**សំរេច**

**មាត្រា ១** : ផ្ទេរសិទ្ធិជូនឯកឧត្តម **គុល ឡោះ** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា ជារដ្ឋមន្ត្រីស្តីទីនៃ ក្រសួងធម្មការ និង សាសនាជំនួយឯកឧត្តម **ឆឿន វណ្ណវ័ត្ត** ត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេសចាប់ពីថ្ងៃទី ០៧ ដល់ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **គុល ឡោះ** ត្រូវទទួលបន្ទុកសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

# II - ការងារបណ្តាក្រសួង

## ប្រកាសអន្តរក្រសួង

### ១ - អន្តរក្រសួងមហាផ្ទៃ - ការពារជាតិ

រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសអន្តរក្រសួងលេខ ២៧៨ ប្រ.ក**

**ស្តីពីល័ក្ខខ័ណ្ឌ នៃការសុំលិខិតអនុញ្ញាតអោយប្រើប្រាស់ អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ**

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ**